**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានីភ្នំពេញ**

**រដ្ឋបាលខណ្ឌដង្កោ**

# សេចក្តីជូនដំណឹង

## ស្តីពីការត្រៀមបង្ការទឹកជំនន់ស្ទឹងព្រែកត្នោតជាយថាហេតុ

អនុវត្តតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២១ **រដ្ឋបាលខណ្ឌដង្កោ** មានកិត្តិយសសូមជម្រាបជូនប្រជាពលរដ្ឋដែលរស់នៅជាប់សណ្តស្ទឹងព្រែកត្នោត ក្នុងនោះមានសង្កាត់ដង្កោ សង្កាត់ព្រៃស សង្កាត់ព្រៃវែង សង្កាត់ក្រាំងពង្រ សង្កាត់ស្ពានថ្ម សង្កាត់ទៀន សង្កាត់សាក់សំពៅ សង្កាត់ជើងឯក សង្កាត់ព្រែកកំពឹស និងសង្កាត់គងនយ ឱ្យបានជ្រាបថា បច្ចុប្បន្នស្ថានភាពទឹកស្ទឹងព្រែកត្នោតបានហក់ឡើងជាបន្តបន្ទាប់ បណ្តាលមកពីជំនន់ផ្នែកខាងលើធ្វើឱ្យទឹកស្ទឹងព្រែកត្នោត ក្នុងភូមិសាស្ត្រខណ្ឌដង្កោ មានកំពស់ដល់កម្រិតត្រូវប្រុងប្រយ័ត្នខ្ពស់។

ដូច្នេះដើម្បីជៀសវាងនូវហានិភ័យដែលបង្កឱ្យខូចខាតទ្រព្យសម្បត្តិ និងអាយុជីវិត សូមបងប្អូនប្រជាពលរដ្ឋដែលរស់នៅតាមសណ្តស្ទឹងព្រែកត្នោត មេត្តាត្រៀមសម្ភារ និងបន្តតាមដានស្ថានភាពទឹកជាប្រចាំជៀសវាងការបាត់បង់សម្ភារ និងអាយុជីវិត។

**រដ្ឋបាលខណ្ឌដង្កោ** សហការជាមួយក្រសួងធនធានទឹក និងឧតុនិយម បន្តតាមដានដោយយកចិត្តទុកដាក់ខ្ពស់បំផុត នូវស្ថានភាពទឹក ដើម្បីជម្រាបជូនប្រជាពលរដ្ឋឱ្យបានជ្រាបជាបន្តបន្ទាប់។

ថ្ងៃ ចន្ទ ៥រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ដង្កោ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០២១

**រដ្ឋបាលខណ្ឌដង្កោ**

**<u>ចម្លងជូន</u>**

- សាលារាជធានីភ្នំពេញ
- មន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ
- ក្រុមប្រឹក្សាខណ្ឌដង្កោ
  (ដើម្បីជូនជ្រាប)
- អធិការដ្ឋាននគរបាលខណ្ឌដង្កោ
- មេបញ្ជាការដ្ឋានកងរាជអាវុធហត្ថខណ្ឌដង្កោ
- សង្កាត់ទាំង១០
  (ដើម្បីផ្សព្វផ្សាយ)
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន ផ្លូវ២១៧ ភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ Tel :(855) 088 850 77 70 E-mail: K_Dongkor@phnom penh.gov.kh